# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីរបស់ នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Apr-2011, 14:38
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបចំពោះសារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើជាបន្ទាន់សុំដោះលែងជាបន្ទាន់ នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ**

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Annebrecht VOSSENBERG
Alejandra CHAPA
(កម្មសិក្សាការីច្បាប់)

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមការពារក្ដីទាំងអស់**

## I សេចក្ដីផ្ដើម

១. អនុលោមតាមមាត្រា ៨.៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការ "ដាក់ឯកសារនៅ អវតក[1] មេធាវីការពារក្ដីជនជាប់ចោទ នួន ជា ("មេធាវីការពារក្ដី") តទៅនេះសូមដាក់ចម្លើយតបនេះ ("ចម្លើយតប") ចំពោះសារណាឆ្លើយតបរបស់ "សហព្រះរាជអាជ្ញា" ទៅនឹងបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើជាបន្ទាន់សុំដោះលែងជាបន្ទាន់ នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ[2] ដែលត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ។

២. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១ មេធាវីការពារក្ដីត្រូវបានជូនដំណឹងថាអង្គជំនុំជម្រះតុលាការកំពូល (អជតក) នឹងមិនធ្វើសវនាការដេញដោលដោយផ្ទាល់មាត់លើបណ្ដឹងសាទុក្ខនេះទេ ("បណ្ដឹងសាទុក្ខ")[3]។ អនុលោមទៅតាមមាត្រា ៨.៤ នៃសេចក្ដីណែនាំអនុវត្ត មេធាវីការពារក្ដីមានរយៈពេល៥ ថ្ងៃនៃប្រតិទិន ដើម្បីដាក់ចម្លើយតប បន្ទាប់ពីថ្ងៃជូនដំណឹងនៃសារណាឆ្លើយតបណាមួយដែលខ្លួនកំពុងឆ្លើយតប។ ចម្លើយតបនេះត្រូវបានដាក់ទាន់ពេលវេលា ។

## II. សារណានៅក្នុងចម្លើយតប

---

[1] សេចក្ដីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មលើកទី៦ ។ អនុលោមតាមមាត្រា ៨.៤ "សំណើចម្លើយតបចំពោះសារណាឆ្លើយតបនឹងត្រូវអនុញ្ញាត នៅក្នុងករណីតែមិនមានការស្នើសុំឲ្យមានការដេញដោលដោយផ្ទាល់មាត់ ហើយការឆ្លើយតបនោះត្រូវដាក់ក្នុងរយៈពេល ០៥ ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងជាភាសាដែលភាគីបានស្នើសុំ អំពីឯកសារដែលអ្នកទាំងនោះត្រូវឆ្លើយតប" ។

[2] ឯកសារលេខ E-50/1/1/1/1, "ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្ដឹងសាទុក្ខ ទៅនឹងបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើជាបន្ទាន់សុំដោះលែងជាបន្ទាន់ នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ, ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ERN 00656590–00656597 ("ចម្លើយតប")។

[3] ឯកសារលេខ E-50/1/1/1 "បណ្ដឹងសាទុក្ខជំទាស់នឹងសេចក្ដីសម្រេចលើសំណើបន្ទាន់សុំឲ្យដោះលែង នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ" ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១ ERN 00649280-00649293 ("បណ្ដឹងសាទុក្ខ")។ សូមមើលផងដែរសារអេឡិចត្រូនិចពី Christopher Mark Ryan (អជតក) ជូន Andrew Ianuzzi (មេធាវីការពារក្ដី) នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១ (អជតក បានសម្រេចដោយអនុលោមតាមវិធាន ១០៩(១) ថាមិនមានសវនាការលើបណ្ដឹងសាទុក្ខរបស់អ្នកឡើយ"។

## ក. សារណាឆ្លើយតបផ្អែកលើបទដ្ឋាននៃការពិនិត្យឡើងវិញដែលមិនត្រឹមត្រូវ ហើយហេតុដូច្នេះ មួយផ្នែកធំនៃការឆ្លើយតបនេះគឺមិនសមហេតុផល

៣. មួយផ្នែកធំនៃសារណាឆ្លើយតបនេះមិនសមហេតុផល ដោយសារវាផ្អែកលើបទដ្ឋាននៃការពិនិត្យឡើងវិញមួយដែលមិនអាចអនុវត្តបានចំពោះករណីនេះ ហើយក៏មិនអាចលើកមកសំអាងដោយមេធាវីការពារក្តីបានដែរ។ នៅពេលវាយតម្លៃបណ្តឹងលើសាទុក្ខនេះ ការិយាល័យសហព្រះរាជអាជ្ញា ("កសព") ហាក់ដូចជាបានយល់ខុសពីវិធានផ្ទៃក្នុងដែលពាក់ព័ន្ធ ស្តីពីការប្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និងជាលទ្ធផល កសព បានផ្អែកលើបទដ្ឋាននៃការពិនិត្យឡើងវិញមួយ ដែលមិនពាក់ព័ន្ធទាំងស្រុង។

៤. វិធាន១០៥(២) ចែងយ៉ាងច្បាស់ថា អាចទទួលយកបាន "បណ្តឹងសាទុក្ខភ្លាមៗ" មួយអាចផ្អែកលើមូលដ្ឋានខុសៗគ្នាមួយ ឬច្រើនជាង នៃមូលដ្ឋានទាំងបី: អាចជា (ជាសង្ខេប) (១) កំហុសអង្គច្បាប់ (២) កំហុសនៅក្នុងការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ឬ (៣) កំហុសនៃអង្គហេតុ[4] ។

៥. កសព ជឿជាក់ដោយភ័ន្តច្រឡំថាបណ្តឹងសាទុក្ខភ្លាមៗអាចផ្អែកលើមូលដ្ឋានតែ (ជាសង្ខេប) កំហុសនៅក្នុងការប្រើឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះសាលាដំបូង ហើយ កសព វាយតម្លៃលើអង្គសេចក្តីរបស់បណ្តឹងសាទុក្ខ ដែលផ្អែកលើបទដ្ឋាននៃការពិនិត្យឡើងវិញ(ដែលមិនអាចអនុវត្តបាន) តែប៉ុណ្ណោះ[5] ។

---

[4] វិធាន ១០៥(២)(ក) វិធាន ១០៥(ខ) និង វិធាន ១០៥(គ) វិធាននីមួយៗចែងយ៉ាងច្បាស់ពីបណ្តឹងសារទុក្ខភ្លាមៗ សមស្របតាមវិធាន ១០៤(ខ)។

[5] សូមមើលចម្លើយតប កថាខណ្ឌ ៣ និង ១០។ ជំហររបស់ កសព ហាក់ដូចជាកើតចេញពីការយល់ខុសនៃវិធាន ១០៤(១) និងមិនពិចារណាទាំងស្រុងពីមាត្រា ១០៥(២)។ វិធាន ១០៤(១) ចែងថា:

> អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសារទុក្ខ ជំទាស់នឹងសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋានដូចខាងក្រម:
>
> (ក) កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃ:ភាពសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ ឬ

៦. ដោយសារតែសារណាឆ្លើយតបរបស់ កសព ផ្អែកលើផ្នែកសំខាន់មួយនៃការបកស្រាយដែលមានកំហុសនេះនៃវិធានផ្ទៃក្នុង។ ជាផលវិបាក កសព ដោះស្រាយសារណានៅក្នុងបណ្តឹងសាទុក្ខនៅក្នុងបរិបទនៃមូលដ្ឋាននៃបណ្តឹងសាទុក្ខ /បទដ្ឋាននៃការពិនិត្យឡើងវិញដែលមិនអាចអនុវត្តបាន។ មេធាវីការពារក្តីមិនដែលចោទប្រកាន់ពីកំហុសនៅក្នុងការប្រើឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។ តាមពិតពាក្យ "ឆន្ទានុសិទ្ធិ" មិនត្រូវបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខឡើយ។ តែបណ្តឹងសាទុក្ខនេះផ្អែកលើមូលដ្ឋាននៃកំហុសអង្គច្បាប់ដោយអង្គជំនុំជម្រះសាលាដំបូង។ ដោយបានផ្អែកលើបទដ្ឋានមិនត្រឹមត្រូវនៃការពិនិត្យឡើងវិញ/មូលដ្ឋាននៃបណ្តឹងសាទុក្ខ កសព ខកខានមិនបានដោះស្រាយកំហុសនៃអង្គច្បាប់នេះទាំងមូលឡើយ។

៧. សម្រាប់មូលហេតុនេះ កថាខណ្ឌទី៣-៥ និងកថាខណ្ឌទី១០-១៥ នៃចម្លើយតប (ដែលផ្អែកដោយផ្ទាល់ និង/ឬ បានពិភាក្សាយ៉ាងវែង និងមិនពាក់ព័ន្ធទៅលើ "កំហុសនៅក្នុងការប្រើឆន្ទានុសិទ្ធិ" និង

---

(ខ) កំហុសនៃអង្គហេតុ ដែលនាំឲ្យសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌ ។

បន្ថែមពីលើនេះ បណ្តឹងសារទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសារទុក្ខ ។

កសព បានយល់ភាសានេះយ៉ាងច្បាស់ក្នុងន័យថា "កំហុសនៃការប្រើឆន្ទានុសិទ្ធិ" គឺជាមូលដ្ឋានតែមួយគត់ដែលបណ្តឹងសារទុក្ខភ្លាមៗអាចយកមកធ្វើជាមូលដ្ឋានបង្អែក ។ កសព បានខកខានមិនបានយល់ពីការបញ្ជាក់ន័យ "បណ្តឹងសាទុក្ខ" នៅក្នុងវិធាន ១០៤(១) ដែលបាននិយាយយោងពី"បណ្តឹងសាទុក្ខភ្លាមៗ" ដែរ ។ ហេតុដូច្នេះ ដូចបណ្តឹងសាទុក្ខធម្មតាដែរ បណ្តឹងសារទុក្ខភ្លាមៗ អាចផ្អែកលើមូលដ្ឋានកំហុសអង្គច្បាប់ និង/ឬ កំហុសនៃអង្គហេតុ ។ បណ្តឹងសាទុក្ខភ្លាមៗ គឺជា "បណ្តឹងសាទុក្ខពិសេស" ក្នុងន័យថាបណ្តឹងសាទុក្ខភ្លាមៗនេះមានមូលដ្ឋានបន្ថែមនៃការពិនិត្យឡើងវិញដែលការណ៍នោះគឺជាកំហុសនៅក្នុងការប្រើឆន្ទានុសិទ្ធិ ប៉ុន្តែ ចំណុចនេះមិនមានន័យថាមូលដ្ឋានបន្ថែមនេះ គឺជាមូលដ្ឋានតែមួយគត់នៃការពិនិត្យឡើងវិញឡើយ។ នេះគឺជាការយល់ឃើញយ៉ាងសមហេតុផលនៃវិធាន ១០៤(១) (ម្យ៉ាងវិញទៀត មិនមានហេតុផលថាហេតុអ្វីបានជាបណ្តឹងសារទុក្ខភ្លាមៗ មិនអាចឬមិនត្រូវផ្អែកលើមូលដ្ឋានកំហុសនៃអង្គច្បាប់ និង/ឬ កំហុសនៃអង្គហេតុ ឡើយ) ហើយបន្ថែមពីលើនេះទៀត ការយល់ ឃើញនេះត្រូវបានគាំទ្រដោយភាសានៃវិធាន ១០៥ ដែលមានចែងមូលដ្ឋានចំនួនបីខុសៗគ្នាសំរាប់បណ្តឹងសារទុក្ខភ្លាមៗ ។

បទដ្ឋាននៃការពិនិត្យឡើងវិញ) គឺមិនសមហេតុផល និងត្រូវតែច្រានចោលដោយអង្គជំនុំជម្រះតុលាការកំពូល នៅពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន[6]។ ជាលទ្ធផល សារណារបស់មេធាវីការពារក្តីលើកំហុសអង្គច្បាប់ដោយអង្គជំនុំជម្រះសាលាដំបូង មិនជំទាស់ដដែល ។

## ខ. ការឃុំខ្លួនលោក នួន ជា ខ្វះមូលដ្ឋានគតិយុត្តិគ្រប់គ្រាន់

៨. កថាខណ្ឌនៅសល់(ទី៦-៩) នៃសារណាចម្លើយតបរបស់សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះសាលាដំបូង "មិនបានភ័ន្តច្រឡំក្នុងការអនុវត្តអំណាចឯករាជ្យរបស់ខ្លួនដើម្បីបន្តការឃុំខ្លួនជនជាប់ចោទនោះទេ"។ កសព បានលើកឡើងថា "គ្មានចំណុចណាមួយក្នុងវិធានផ្ទៃក្នុងបានគាំទ្រដល់ការអះអាងដែលថានៅមុនការកើតឡើងនៃទម្រង់ណាមួយនៃកំហុសខាងនីតិវិធីនៅក្នុងសាលដីកាសម្រេច លើការឃុំខ្លួនរបស់អង្គបុរេជំនុំជម្រះ បានធ្វើឲ្យមោឃៈភាពដល់ការបន្តការឃុំខ្លួនជនជាប់ចោទ ឬអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទស្របតាមអំណាចឯករាជ្យរបស់ខ្លួននោះឡើយ"។ កសព បានលើកឡើងទៀតថា"[...]ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើសេចក្តីសន្និដ្ឋានខុសគ្នាទាក់ទងនឹងសុពលភាពនៃផ្នែកការឃុំខ្លួននៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់អង្គបុរេជំនុំជម្រះ ក៏ដោយ [អង្គជំនុំជម្រះសាលាដំបូង] បានអនុវត្តអំណាចរបស់ខ្លួនយ៉ាងត្រឹមត្រូវស្របតាមវិធាន៨២(២) នៃវិធានផ្ទៃក្នុងដើម្បីបន្តឃុំខ្លួនជនជាប់ចោទដែរ"[7]។

៩. និយាយឲ្យខ្លីទៅ កសព អះអាងថាអង្គជំនុំជម្រះសាលាដំបូងមានអំណាចបង្គាប់ឲ្យបន្តឃុំខ្លួន

---

[6] ជាពិសេស ដោយផ្ទុពីការអះអាងរបស់ កសព មេធាវីការពារក្តីមិនត្រូវការបង្ហាញកំហុសការប្រើឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះសាលាដំបូងឡើយ ហើយមិនខ្លួនក៏មិនត្រូវការបង្ហាញពីការប៉ះពាល់ដល់ការជនជាប់ចោទដែរ ។ ប៉ុន្តែ មេធាវីការពារក្តីត្រូវបង្ហាញពីកំហុសអង្គច្បាប់ ដែលនាំឲ្យមោឃភាពសេចក្តីសម្រេច ។ នៅក្នុងបណ្តឹងសារទុក្ខរបស់ខ្លួន មេធាវីការពារក្តីបានធ្វើរួចមកហើយ។

[7] សម្គាល់៖ មេធាវីការពារក្តីតាមពិតទៅ មិនដែលជំទាស់នឹងសុពលភាពនៃការឃុំខ្លួនក្នុងដីកាដំណោះស្រាយនោះទេ ដោយសារតែសុពលភាពនេះមិនទាក់ទងនឹងសារណា។ បន្ទាប់មកការឃុំខ្លួននេះត្រូវអស់សុពលភាពបន្ទាប់ពីរយៈពេលបួនខែដោយអនុលោមតាមវិធាន ៦៨(៣)។

នួន ជា សមស្របតាមវិធាន ៨២ ទោះបីជាអាចមានកំហុសខាងនីតិវិធីកាលពីមុនក៏ដោយ។ នៅក្នុងករណីនេះ កសព ខកខានមិនបានទទួលស្គាល់ (ដូច្នេះហើយមិនបានដោះស្រាយ) សារណារបស់មេធាវីការពារក្ដីស្ដីពីលក្ខណៈពិសេសនៃ "កំហុសខាងនីតិវិធី"។ សាលដីកាដែលគ្មានសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ មិនត្រឹមតែជា"កំហុសខាងនីតិវិធីដែលជៀងមិនរួច" ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការអនុវត្តដោយចេតនាដោយអង្គបុរេជំនុំជម្រះ ដើម្បីគេចវេសពីការការពារដែលវិធានផ្ទៃក្នុងបានផ្ដល់ឲ្យជនជាប់ចោទទៀតផង[8]។ ការរំលោភ*ដោយចេតនា* ដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទពីសំណាក់អង្គភាពតុលាការនៅ អវតក (អង្គបុរេជំនុំជម្រះ) ដែលផ្ដើមចេញពីគោលបំណងដើម្បីបន្តឃុំខ្លួនជនជាប់ចោទបណ្ដោះអាសន្ន បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អំណាចរកាត់សេចក្ដីរបស់អង្គភាពតុលាការក្រោយទៀត (អង្គជំនុំជម្រះសាលាដំបូង) ក្នុងការប្រកាន់យក និងបន្តការឃុំខ្លួន (ដែលមានកំហុសផ្នែកច្បាប់) ប្រឆាំងជនជាប់ចោទ។ ម្យ៉ាងទៀត ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបញ្ហានេះត្រូវបានរលាយសាបសូន្យដោយសារតែសេចក្ដីសម្រេចដែលមិនសមហេតុផលកាលពីមុនរបស់អង្គបុរេជំនុំជម្រះ ដោយការបំពានដោយចេតនាទាំងលើខ្លឹមសារ និងស្មារតីនៃវិធានផ្ទៃក្នុង ។

១០. ជាងនេះទៅទៀត សេចក្ដីសម្រេចបន្តឃុំខ្លួន គឺផ្អែកដោយផ្ទាល់លើកំហុសផ្នែកអង្គច្បាប់ដែលប្រព្រឹត្តឡើងដោយអង្គជំនុំជម្រះសាលាដំបូង ហើយហេតុដូច្នេះ វាមានទំនាក់ទំនងគ្នាយ៉ាងច្របូកច្របល់ជាមួយកំហុសផ្នែកច្បាប់នេះ ហើយហេតុដូច្នេះ សេចក្ដីសម្រេចនេះមានកំហុសយ៉ាងធ្ងន់ធ្ងរ។ និយាយជារួមទៅ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង បានទទួលស្គាល់*យ៉ាងត្រឹមត្រូវ*នូវការបកស្រាយ និងគោលបំណងនៃវិធាន៦៨ នោះអង្គជំនុំជម្រះសាលាដំបូងប្រហែលជាមិនបន្តឃុំខ្លួនលោក នួន ជា ឡើយ ហើយអង្គជំនុំជម្រះសាលាដំបូងនឹងយល់ថាការដោះលែងលោក នួន ជា ឲ្យនៅក្រៅឃុំជាបន្ទាន់ គឺជាដំណោះស្រាយសមស្របតែមួយគត់កាលពីថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១១ (ហួសកំណត់ក្នុងរយៈពេល៤ខែ) នៅបន្ទាប់ពីដីកាឃុំខ្លួនបណ្ដោះអាសន្នចេញដោយការិ

[8] សូមមើលបណ្ដឹងសាទុក្ខ, កថាខណ្ឌទី២២ ដល់ ២៣។ ឯកសារលេខ D-427/3/12 "សេចក្ដីសម្រេចលើបណ្ដឹង អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ERN 00634916-00634922 (មិនមានសម្អាងហេតុ) និងបន្ទាប់មកមាន ឯកសារលេខ D-427/3/15"សេចក្ដីសម្រេចលើបណ្ដឹង អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00644462-00644571 (មានសម្អាងហេតុ)។

យាល័យសហចៅក្រមស៊ើបអង្កេត(“កសចស”) នៅក្នុងដីកាដំណោះស្រាយ “អស់សុពលភាព”។ ការដោះលែងគឺជាជម្រើសដូចគ្នាតែមួយគត់នៅថ្ងៃសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និង នៅថ្ងៃដែលប្រកាសពីសេចក្តីសម្រេចរបស់ខ្លួន និងដូចដែលបានលើកឡើងក្នុងពេលនេះ។ ដូចដែលបានពន្យល់ក្នុងបណ្តឹងសាទុក្ខ បញ្ហានេះបង្កឡើងមួយផ្នែកដោយសារតែប្រការដែលថាវិធាន៦៨ ត្រូវតែចាត់ទុកថាជា *វិធានពិសេស* នៅពេលគេនិយាយអំពីការឃុំខ្លួនដែលកើតចេញមកពីដីកាដំណោះស្រាយ[9]។ ករណីនេះ មានន័យថាអង្គជំនុំជម្រះសាលាដំបូង មិនមានឯករាជ្យក្នុងការអនុវត្តអំណាចរបស់ខ្លួន សមស្របតាមវិធាន ៨២ ប៉ុន្តែបែរជា (លើកឡើង) និងជំទាស់ទៅនឹងបញ្ញត្តិយ៉ាងច្បាស់នៃវិធាន៦៨ ដែលបានចែងពីការដោះលែងជនជាប់ចោទជាបន្ទាន់[10] ។

១១. ក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវបានបង្ខំដោយការទទូចរបស់ កសព ទាក់ទងនឹងការប្រើប្រាស់ “ឆន្ទានុសិទ្ធិ” បណ្តឹងសាទុក្ខមិនវិលវល់ដោយការប្រើត្រឹមត្រូវ ឬមិនត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ ប៉ុន្តែនីតិវិធីនេះពាក់ព័ន្ធនឹងការភ័ន្តច្រឡំផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ព្រោះអង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានទទួលស្គាល់អ្វីដែលបានចែងក្នុងវិធាន៦៨ (សេចក្តីសម្រេច៖ដោះលែងជនជាប់ចោទ ក្នុងរយៈពេល៤ខែបន្ទាប់ពីដីកា

---

[9] បណ្តឹងសាទុក្ខ, កថាខណ្ឌទី៣៣។

[10] ម្យ៉ាងវិញទៀត វានឹងក្លាយជាដំណោះស្រាយមួយដែលមានតែភាពអវិជ្ជមានចំពោះខ្លឹមសារនៃវិធានផ្ទៃក្នុង ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់សវនាការមួយដែលដែលគេចាត់ទុកថាចាំបាច់*ដោយសារ*តែការភ័ន្តច្រឡំផ្នែកច្បាប់របស់អង្គបុរេជំនុំជម្រះ (ដែលការភ័ន្តច្រឡំនេះបានរំលោភសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដោយការបដិសេធមិនដោះលែងគាត់នៅថ្ងៃដែលគាត់ត្រូវគេដោះលែង) ដើម្បីជួសជុលការរំលោភនេះដោយគ្រាន់តែចេញដីកាបន្តឃុំខ្លួនស្របតាមវិធាន៨២ ជាថ្មីម្តងទៀតនោះ។ (នេះគឺជាស្ថានភាពមួយដែលត្រូវតែបែងចែកឲ្យដាច់ពីគ្នារវាងស្ថានភាពដែលក្នុងនោះជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលដែលសវនាការបឋមបានចាប់ផ្តើមបន្ទាប់ពីត្រូវបានដោះលែងស្របតាមអនុភាពនៃវិធាន៦៨។ *ករណីនេះ* ត្រូវតែជាស្ថានភពមួយដែលអ្នកព្រៀងវិធានផ្ទៃក្នុងត្រូវតែចាំក្នុងចិត្ត។ ចៃដន្យ វាអាចថាអង្គជំនុំជម្រះសាលាដំបូង នឹងមិនបង្គាប់ឲ្យចាប់ខ្លួនលោក នួន ជានៅពេលដែលគាត់បង្ហាញវត្តមានក្នុងសវនាការបឋមឡើយ ដូច្នេះហើយ ការបង្ហាញខ្លួននេះ នឹងបញ្ជាក់ថាការបារម្ភពីការរត់គេចគឺគ្មានមូដ្ឋានច្បាស់លាស់ឡើយ។

ដំណោះស្រាយ លើកលែងតែមានសេចក្តីសម្រេចដែលមានសំអាងហេតុ [11] ពីអង្គបុរេជំនុំជម្រះក្នុងការបន្តឃុំខ្លួន) ។

១២. ជាងនេះទៀត ក្នុងកថាខណ្ឌទី៨ និង៩ កសព បាននិយាយអំពី "ភាពត្រឹមត្រូវ" នៃការបន្តការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន ការមិនបានលើកឡើងរបស់មេធាវីការពារក្តីនូវការប្រែប្រួលក្នុងកាលៈទេសៈ និងអំពីការដែលថាគ្មានចំណុចណាមួយក្នុងបណ្តឹងសាទុក្ខដែលមេធាវីការពារក្តីអះអាងថាមានមូលដ្ឋានភស្តុតាងមិនគ្រប់គ្រាន់អំពីការបន្តឃុំខ្លួនជនជាប់ចោទ។ ជាថ្មីម្តងទៀត កសព ខកខានមិនបានទទួលស្គាល់ការសន្និដ្ឋានដ៏សំខាន់មួយក្នុងចំណោមការសន្និដ្ឋានដទៃទៀតក្នុងបណ្តឹងសាទុក្ខដែលបានលើកឡើងថាវាមិនចាំបាច់វាយតម្លៃពីមូលហេតុលើការឃុំខ្លួន (ឬក៏វាយតម្លៃថាតើ កសចស អបជ និង ឬ អជសជ បានវាយតម្លៃហេតុផលនេះបានគ្រប់គ្រាន់ ឬអត់ទេ)។ វិធាន៦៨ (៣) មិនបានលើកឡើងពីមូលហេតុទាំងនេះទេ ប៉ុន្តែវិធាននេះនិយាយតែអំពីការអស់សុពលភាពនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ កសចស បន្ទាប់ពីផុតរយៈពេល៤ខែប៉ុណ្ណោះប្រសិនបើគ្មានសេចក្តីសម្រេចមានសំអាងហេតុណាមួយ ត្រូវបានធ្វើឡើងក្នុងអំឡុងពេលនោះទេ។ ថាតើមូលហេតុនៃការឃុំខ្លួនកើតមានឬអត់នោះ គឺមិនពាក់ព័ន្ធឡើយ ។

**គ. គោលការណ៍ស្តីពីដំណោះស្រាយជាស្ពាន** *( Ultimum remedium)*

១៣. ទោះបីជានៅក្នុងជើងទំព័រ កសព បានជំទាស់ទៅនឹងការអំពាវនាវរបស់មេធាវីការពារក្តីឱ្យអនុវត្តគោលការណ៍ស្តីពីដំណោះស្រាយស្ពាន[12]។ ដើម្បីគាំទ្រគោលជំហររបស់ខ្លួន កសព បានលើកឡើងពីមាត្រាមួយចំនួនក្នុងវិធានផ្ទៃក្នុងដែលអះអាងថាគោលការណ៍ស្តីពីដំណោះស្រាយស្ពាន គឺមានភាពពាក់ព័ន្ធដែលមានដែនកំណត់នៅចំពោះមុខ អវតក ហើយជាងនេះទៅទៀត កសព បានលើកឡើងពីការ "អនុវត្តអន្តរជាតិ" ដែលនឹងគាំទ្រដល់គោលជំហររបស់ខ្លួន។

១៤. មេធាវីការពារក្តីសូមលើកឡើងជាថ្មីម្តងទៀតថាគោលការណ៍ស្តីពីដំណោះស្រាយស្ពានត្រូវបានបង្កើតឡើងយ៉ាងរឹងមាំក្នុងប្រព័ន្ធច្បាប់កម្ពុជា និងនៅពេលនោះ យើងនឹងលើកឡើងពីមាត្រា២០៣

---

[11] មេធាវីការពារក្តី កត់សម្គាល់ឃើញថា គ្មានចំណុចណាមួយដែល កសព បានជំទាស់ថាសាលដីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងដីកាដំណោះស្រាយចាំបាច់ត្រូវតែមានសំអាងហេតុនោះទេ។

[12] ចម្លើយតប ជើងទំព័រទី ២០។

នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា៖ "ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្នក្នុងលក្ខខណ្ឌដែលបានចែងក្នុងផ្នែកនេះ[13]"។ ការបកស្រាយនេះ ផ្ទុះបញ្ចាំងពីជំនឿយ៉ាងមុតមាំលើគោលការណ៍ស្តីពីដំណោះស្រាយស្ពាន។ ម្យ៉ាងវិញទៀត និងសំខាន់ជាងនេះទៅទៀត គោលការណ៍នេះបានឆ្លុះបញ្ចាំងនៅគ្រប់មាត្រានៃវិធានផ្ទៃក្នុងដែលពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខនៅពេលបច្ចុប្បន្នដែលវិធាននេះ គឺ ៦៨(៣) ដែលចែងពីការអស់សុពលភាពដោយស្វ័យប្រវត្តិនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ កសចស បន្ទាប់ពីរយៈពេល៤ខែបានកន្លងផុត។ ដូច្នេះការបញ្ជាក់យ៉ាងច្បាស់អំពីគោលការណ៍ស្តីពីដំណោះស្រាយស្ពាន ត្រូវតែបានជូនដំណឹងដល់ក្រុមវាយតម្លៃរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីបណ្តឹងសាទុក្ខនេះ (និងគួរតែបានជូនដំណឹងដល់ក្រុមវាយតម្លៃអំពីបញ្ហាដែលបង្កឡើងដោយអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង ក្នុងដំណាក់កាលមុនដំបូងនៃដំណើរការនីតិវិធី ។

## III. សេចក្តីសន្និដ្ឋាន

១៩. អាស្រ័យលើមូលហេតុដូចដែលបានគូសបញ្ជាក់ខាងលើ និងមូលហេតុដែលបានលើកឡើងក្នុងបណ្តឹងសាទុក្ខ មេធាវីការពារក្តីស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើមោឃៈភាពសេចក្តីសម្រេច (ឬ កែតម្រូវសេចក្តីសម្រេចដោយលទ្ធផលដូចគ្នា) របស់អង្គជំនុំជម្រះសាលាដំបូង និងបង្គាប់ឱ្យដោះលែងលោក នួន ជា ជាបន្ទាន់ ។

សហមេធាវីការពារក្តីលោក **នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE

[13] មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (គូសបញ្ជាក់បន្ថែម)។